ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង**
**ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម**

# របាយការណ៍
# ស្តីពី ការបូកសរុបលទ្ធផលការងារប្រចាំត្រីមាស ឆ្នាំ២០១៧

## ១ ស្ថានភាពរួម

ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបងបានបំពេញការងារក្នុងតួនាទីជាភ្នាក់ងារសម្របសម្រួលក្នុងការបង្កើត និងជំរុញសហគមន៍កសិកម្ម ដែលបច្ចុប្បន្នសហគមន៍កសិកម្មក្នុងខេត្តបាត់ដំបងមានចំនួន ៧៨សហគមន៍ ស្ថិតនៅតាមបណ្តាស្រុក-ក្រុងទាំង ១៤ ។ ក្រៅពីការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្មជាអ្នកសម្របសម្រួល និងត្រួតពិនិត្យតាមដានដល់សហគមន៍កសិកម្ម ក៏មានអង្គការដៃគូអភិវឌ្ឍន៍នានាដែលបាននឹងកំពុងគាំទ្រដល់ការអភិវឌ្ឍន៍សហគមន៍កសិកម្មផងដែរ។ បណ្តាអង្គការទាំងនោះរួមមាន៖ អង្គការទស្សនៈពិភពលោក, អង្គការការីតាស, អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍, អង្គការក្រុមអភិវឌ្ឍន៍ភូមិ, សមាគមដើម្បីអភិវឌ្ឍន៍សហគមន៍ខ្មែរជាដើម ។

ជាទូទៅសហគមន៍កសិកម្មមានមុខរបរចម្បងលើសេវាកម្មឥណទាន ដោយផ្តល់ប្រាក់កម្ចី និងទទួលប្រាក់សន្សំសម្រាប់សមាជិក។ មុខរបរសំខាន់មួយចំនួនទៀតដែលសហគមន៍កសិកម្មកំពុងដំណើរការរួមមាន៖ ផ្គត់ផ្គង់ធាតុចូលកសិកម្ម, ទីផ្សារ កសិផល, ផលិតកម្មដំណាំ និងសត្វ, ផលិតពូជស្រូវ, ឡសម្ងួតស្រូវ, លក់ប្រេងឥន្ធនៈ និងលក់គ្រឿងបរិភោគជាដើម។

## ២ ស្ថានភាពបុគ្គលិក

មន្រ្តីបំពេញការងារនៅការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្មមានចំនួន ១២នាក់ ស្រីចំនួន ១នាក់ ក្នុងនោះមានមន្រ្តីចំនួន ០៣នាក់ត្រូវបានបែងចែកឲ្យទៅប្រចាំការនៅស្រុកមោងឫស្សី ១នាក់, ស្រុកថ្មគោល ១នាក់, និងស្រុកបវេល ១នាក់ ។ មន្ត្រីការិយាល័យទាំងអស់មានប្រភេទក្របខណ្ឌ និងកម្រិតបណ្តុះបណ្តាលខាងក្រោម៖

- ប្រភេទក្របខណ្ឌ(ក)ចំនួន ០២នាក់, ក្របខណ្ឌ(ខ)ចំនួន ០២នាក់, និងក្របខណ្ឌ(គ)ចំនួន ០៨នាក់,
- ថ្នាក់អនុបណ្ឌិតចំនួន០២នាក់, ថ្នាក់បរិញ្ញាបត្រចំនួន ០៤នាក់, ថ្នាក់មធ្យមចំនួន ០២នាក់, និងថ្នាក់បឋមចំនួន ០៤នាក់ ។

ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម ក៏បានសហការជាមួយការិយាល័យកសិកម្មស្រុកទាំង១៣ និងក្រុង១ ដើម្បីរួមគ្នាជួយអភិវឌ្ឍសហគមន៍កសិកម្មតាមបណ្តាលស្រុក និងក្រុងផងដែរ ។

## ៣ សកម្មភាព និង លទ្ធផលសម្រេចបាន

### ក ការរៀបចំពិធីចែកវិញ្ញាបនបត្រទទួលស្គាល់សហគមន៍កសិកម្ម

ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម បានរៀបចំពិធីចែកវិញ្ញាបនបត្រទទួលស្គាល់សហគមន៍កសិកម្មគំរូថ្មីជូនដល់សហគមន៍កសិកម្មទាំង ៧៨សហគមន៍ក្នុងខេត្តបាត់ដំបង ដោយទទួលបានការឧបត្ថម្ភពី អង្គការទស្សនៈ

ពិភពលោកកម្ពុជាប្រចាំខេត្តបាត់ដំបង និងទទួលបានការអញ្ជើញចូលរួមពី លោក **អៀ ឯកសារ** អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ជាគណៈអធិបតី ដែលមានអ្នកចូលរួមសរុបចំនួន ៩០នាក់ ស្រី ២២នាក់ ។

**ខ ការផ្សព្វផ្សាយច្បាប់សហគមន៍កសិកម្ម**

មន្ត្រីការិយាល័យចំនួន ០៤នាក់ បានចុះផ្សព្វផ្សាយច្បាប់សហគមន៍កសិកម្មបានចំនួន ០៣លើក ដែលមានអ្នកចូលរួមសរុបចំនួន ១៦០នាក់ ស្រី ៦៨នាក់ នៅឃុំអន្លង់រុន ស្រុកថ្មគោល, ឃុំព្រៃចាស់ និងឃុំកោះជីវាំងស្រុកឯកភ្នំ។

**គ ការចុះបញ្ជីទទួលស្គាល់សហគមន៍កសិកម្ម**

បានចុះបញ្ជីទទួលស្គាល់សហគមន៍កសិកម្មថ្មីចំនួន ០១សហគមន៍ ដែលមានឈ្មោះថា សហគមន៍កសិកម្មខាំ-កូគីឡូ៣៨ ស្ថិតនៅភូមិគីឡូ៣៨ ឃុំត្រែង ស្រុករតនមណ្ឌល មានសមាជិកសរុប ៥១នាក់ ស្រី ១៥នាក់ ហ៊ុនសរុបចំនួន ៦១ហ៊ុន, តម្លៃក្នុងមួយហ៊ុន ១០០,០០០រៀល, និងមានដើមទុនសរុបចំនួន ៦,១០០,០០០រៀល សម្រាប់ប្រកបមុខរបរលក់ចំណីសត្វ និងចិញ្ចឹមមាន់ជាដើម។

**ឃ ការចូលរួមមហាសន្និបាតរបស់សហគមន៍កសិកម្ម**

បានចូលរួម និងសម្របសម្រួលមហាសន្និបាតរបស់សហគមន៍កសិកម្មចំនួន ០៥លើក សរុបអ្នកចូលរួមចំនួន ៣៧៣នាក់ ស្រី ១៧២នាក់ រួមមាន៖ សហគមន៍កសិកម្មមានជ័យរស្មីរុងរឿង, ទឹកចិត្តកសិករគារមានជ័យ, ខាំ-កូគីឡូ៣៨, ពន្លឺថ្មីសាមគ្គី, និងរំដួលភ្នំព្រឹក ។

**ង ការដោះស្រាយវិវាទ**

បានសម្របសម្រួលដោះស្រាយវិវាទសហគមន៍កសិកម្មបានចំនួន ២លើកគឺ៖

- សហគមន៍កសិកម្មត្រែងជោគជ័យរស្មីផ្លូវមាស៖ បានសម្របសម្រួលដោះស្រាយវិវាទរវាងសហគមន៍កសិកម្មជាមួយនឹងក្រុមហ៊ុនជេ ស៊ី ហ្វូដ ស្តីពីកិច្ចសន្យាលក់នៅឆ្នាំ២០១៤។
- សហគមន៍កសិកម្មពន្លឺថ្មីពេជ្រចិន្តា៖ បានសម្របសម្រួលដោះស្រាយវិវាទរវាងសហគមន៍កសិកម្មជាមួយអតីតបេឡាករ ដែលរងការចោទធ្វើឲ្យបាត់ប្រាក់សរុបចំនួន ៤១,០៥៥,៧០០រៀល កាលពីឆ្នាំ២០១៥ ។

**ច ការជូនសហគមន៍កសិកម្ម និងកសិករប្រលងប្រណាំងថ្នាក់ជាតិប្រចាំឆ្នាំ**

មន្ត្រីការិយាល័យចំនួន ០១នាក់ បានចូលរួមដំណើរជាមួយថ្នាក់ដឹកនាំមន្ទីរក្នុងការដឹកនាំសហគមន៍កសិកម្ម និងកសិករឆ្នើមចូលរួមប្រលងប្រណាំងថ្នាក់ជាតិប្រចាំឆ្នាំនៅអគ្គនាយកដ្ឋានកសិកម្ម និងបានចូលរួមជូនគណៈកម្មការដាក់ពិន្ទុវាយតម្លៃសហគមន៍ និងកសិករឆ្នើមដល់ទីកន្លែងរស់នៅរបស់បេក្ខជនជាប់លើកទី១ ។

**ឆ ការចូលរួមសិក្ខាសាលា/ វគ្គបណ្តុះបណ្តាល**

ថ្នាក់ដឹកនាំ និងមន្ត្រីការិយាល័យសរុបចំនួន ០៣នាក់ បានចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាចំនួន ០៤លើករួមមាន៖ ភាពជាអ្នកដឹកនាំនិងគ្រប់គ្រងសហគមន៍កសិកម្ម ០១លើក, ការគ្រប់គ្រងនិងប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាពសម្រាប់ដំណាំកសិកម្ម ០១លើក, ប្រព័ន្ធព័ត៌មានទីផ្សារស្រូវអង្ករ ០១លើក, និងស្តង់ដារកម្ពុជាសម្រាប់អង្ករផ្ការំដួល និងផ្កាចំន្ទសែនសរ ០១លើក។

**ជ ការសហការ**

បានសហការសរុបចំនួន ១៦លើក ជាមួយអង្គការចំនួន ០៤ ការិយាល័យជំនាញចំនួន ០១ និងនាយកដ្ឋានចំនួន ០១ រួមមាន៖

- អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍៖ បានសហការចំនួន ០៣លើក ក្នុងការសម្របសម្រួលវគ្គបណ្តុះបណ្តាលផែនការសកម្មភាពប្រចាំឆ្នាំសម្រាប់សហគមន៍កសិកម្ម ០១លើក និងសម្របសម្រួលពិភាក្សាចងក្រងជាបណ្តាញសហគមន៍កសិកម្ម ០២លើក

- អង្គការទស្សនៈពិភពលោកកម្ពុជា៖ បានសហការចំនួន ០៣លើក ក្នុងការចូលរួមនិងសម្របសម្រួលសហគមន៍កសិកម្មធ្វើទស្សនកិច្ចសិក្សាលើក្រុមកសិករផលិតបន្លែសរីរាង្គ ១លើក, និងរៀបចំពិធីចែកវិញ្ញាបនបត្រទទួលស្គាល់សហគមន៍កសិកម្ម ១លើក, និងសម្របសម្រួលរៀបចំផែនការអាជីវកម្មសហគមន៍កសិកម្ម ០១លើក
- អង្គការអ្នកជិតខាងល្អកម្ពុជា (Good Neighbors Cambodia)៖ បានសហការចំនួន ០៣លើក ស្តីពីការផ្សព្វផ្សាយច្បាប់សហគមន៍កសិកម្ម
- KOPIA ( Korean Program on International Agriculture, កម្មវិធីកូរ៉េ សម្រាប់កសិកម្មអន្តរជាតិ) ចំនួន ០២លើក ក្នុងការផ្សព្វផ្សាយច្បាប់សហគមន៍កសិកម្ម ១លើក និង ផ្សព្វផ្សាយលក្ខន្តិកៈគំរូ និងបទបញ្ជាផ្ទៃក្នុងគំរូសម្រាប់សហគមន៍កសិកម្ម ១លើក
- ការិយាល័យអភិវឌ្ឍន៍មុខជំនួញ និងទីផ្សារ នៃនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម៖ បានចំនួន ០១លើក ក្នុងការធ្វើទស្សនកិច្ចសិក្សាសហគមន៍កសិកម្មក្នុងខេត្តប៉ៃលិន
- នាយកដ្ឋានសាកវប្បកម្មនៃអគ្គនាយកដ្ឋានកសិកម្ម៖ បានសហការចំនួន ០៤លើក ក្នុងរៀបចំបង្ហាញ៤កន្លែងលើកសិករ៤គ្រួសារ អំពីបន្លែសរីរាង្គ ។

**ឈ ការជួបពិភាក្សាពិគ្រោះយោបល់**

បានជួបពិភាក្សាពីស្ថានភាពទាក់ទងនឹងសហគមន៍កសិកម្មជាមួយអង្គការដៃគូផ្សេងៗចំនួន ០៥លើក៖

- អង្គការ KOICA៖ បានចំនួន ០១លើក ដើម្បីស្វែងយល់ពីស្ថានភាពសហគមន៍កសិកម្មក្នុងខេត្តបាត់ដំបង និងការរៀបចំសហការគាំទ្រសហគមន៍កសិកម្ម នៅឆ្នាំ២០១៨ ។
- អង្គការ VSO (Volunteer Services Overseas)៖ បានចំនួន ០១លើក ស្តីពីការវាយតម្លៃពាក់កណ្តាលគម្រោងខ្សែសង្វាក់ផលិតកម្មដំណាំស្រូវ (IMAP) និងការគាំទ្រដល់សហគមន៍កសិកម្ម
- សហគមន៍សន្សំប្រាក់ក្នុងស្រុកថ្មគោល និងស្រុកបាណន់ ០៣លើក ស្តីពីនីតិវិធីបង្កើតសហគមន៍កសិកម្ម និងការបំប្លែកខ្លួនពីសហគមន៍សន្សំប្រាក់មកជាសហគមន៍កសិកម្មវិញ។

**ញ ស្ថិតិសហគមន៍កសិកម្ម**

តារាងសង្ខេបទិន្នន័យសហគមន៍កសិកម្មតាមស្រុក/ក្រុង

| ល.រ | ស្រុក/ក្រុង | ចំនួនសហគមន៍ | សមាជិកសហគមន៍ | | អ្នកដឹកនាំសហគមន៍ | | ដើមទុន (រៀល) |
|---|---|---|---|---|---|---|---|
| | | | សរុប(នាក់) | ស្ត្រី (នាក់) | សរុប(នាក់) | ស្ត្រី (នាក់) | |
| ១ | ស្រុកមោងឫស្សី | 7 | 821 | 420 | 64 | 17 | 231,571,200 |
| ២ | ស្រុករុក្ខគិរី | 4 | 268 | 167 | 34 | 17 | 23,290,000 |
| ៣ | ស្រុកគាស់ក្រឡ | 8 | 1,381 | 707 | 76 | 24 | 405,810,500 |
| ៤ | ស្រុកសង្កែ | 6 | 692 | 291 | 51 | 13 | 356,619,180 |
| ៥ | ក្រុងបាត់ដំបង | 2 | 172 | 123 | 13 | 8 | 64,422,400 |
| ៦ | ស្រុកឯកភ្នំ | 2 | 244 | 147 | 16 | 7 | 100,380,609 |
| ៧ | ស្រុកថ្មគោល | 6 | 354 | 190 | 45 | 13 | 57,067,300 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៨ | ស្រុកបវេល | 6 | 913 | 415 | 51 | 22 | 528,202,780 |
| ៩ | ស្រុកភ្នំព្រឹក | 6 | 630 | 319 | 49 | 25 | 519,441,000 |
| ១០ | ស្រុកកំរៀង | 5 | 838 | 414 | 40 | 16 | 766,056,760 |
| ១១ | ស្រុកសំពៅលូន | 6 | 744 | 477 | 44 | 18 | 1,069,527,920 |
| ១២ | ស្រុកសំឡូត | 6 | 1,674 | 1,160 | 65 | 29 | 844,418,300 |
| ១៣ | ស្រុករតនមណ្ឌល | 6 | 685 | 352 | 59 | 17 | 415,710,050 |
| ១៤ | ស្រុកបាណន់ | 8 | 1,302 | 725 | 69 | 22 | 976,842,120 |
| សរុប | | 78 | 10,802 | 5,842 | 676 | 248 | 7,234,824,919 |

## ដ្យាក្រាមទី ១ ចំនួនសហគមន៍កសិកម្មផ្អែកតាមទំហំទ្រព្យសកម្មសរុប




## ដ្យាក្រាមទី ២ចំនួនសហគមន៍កសិកម្មផ្អែកតាមប្រភេទទ្រព្យសម្បត្តិ



## ដ្យាក្រាមទី ៣ ចំនួនសហគមន៍កសិកម្មផ្អែកតាមភាពដំណើរការមុខរបរ




## ដ្យាក្រាមទី ៤ ចំនួនសហគមន៍កសិកម្មផ្អែកតាមប្រភេទមុខរបរ




## ៤ បញ្ហាប្រឈម

- សមត្ថភាពថ្នាក់ដឹកនាំសហគមន៍ក្នុងការកត់ត្រាបញ្ជីគណនេយ្យនៅមានកម្រិតទាប
- អ្នកដឹកនាំសហគមន៍កសិកម្មមួយចំនួនអសកម្ម
- សហគមន៍កសិកម្មភាគច្រើនមិនទាន់ធ្វើមហាសន្និបាតប្រចាំឆ្នាំ និងរបាយការណ៍ប្រចាំឆ្នាំ។

## ៥ ទិសដៅបន្ត

- ចូលរួមមហាសន្និបាតសហគមន៍កសិកម្ម
- ជួយអន្តរាគមន៍ដល់សហគមន៍កសិកម្មដែលជួបបញ្ហាត្រូវដោះស្រាយ
- បន្តតាមដានសកម្មភាពសហគមន៍កសិកម្ម
- បន្តសហការណ៍នឹងអង្គការនានា
- ផ្សព្វផ្សាយលក្ខន្តិកៈគំរូ និងបទបញ្ជាផ្ទៃក្នុង គំរូសម្រាប់សហគមន៍កសិកម្ម បង្កើតថ្មី
- បណ្តុះបណ្តាលវគ្គភាពជាអ្នកដឹកនាំដល់សហគមន៍កសិកម្ម

- បណ្តុះបណ្តាលវគ្គផែនការសកម្មភាពប្រចាំឆ្នាំ និងផែនការហិរញ្ញវត្ថុប្រចាំឆ្នាំ ដល់សហគមន៍កសិកម្ម
- ធ្វើបច្ចុប្បន្នភាពទិន្នន័យរបស់សហគមន៍កសិកម្មបន្ត ។

បាត់ដំបង,ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧

បានឃើញ និងគោរពជូន អ្នករៀបចំរបាយការណ៍

ដើម្បីជូនជ្រាប

បានឃើញ និង ឯកភាព បាត់ដំបង,ថ្ងៃទី ខែមីនា ឆ្នាំ២០១៧

បាត់ដំបង,ថ្ងៃទី ខែ ឆ្នាំ ២០១៧ **ប្រធានការិយាល័យ** ឆុំ សុភក្រ្តា

**ប្រធានមន្ទីរ**